# អត្ថបទ ធម៌ទេសនា

# ស្ដីអំពី

# “ សីល ”

ភិក្ខុ **កែវ-អ៊ុន ឬ សំអៀន**

“ **អភិញ្ញានសីលោ** ”

វត្ត **សម្ដេចព្រះមហាឃោសានន្ទ**

“សាខាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

ព្រហស្បតិ៍៨កើតចេត្រ,ម្សាញ់បញ្ចស័កព.ស.២៥៥៦;ទី១៣មេសាគ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង

# អត្ថបទធម៌ ស្ដីអំពីសីល

សាធុសប្បុរសទាំងឡាយ!ថ្ងៃនេះជាថ្ងៃសីលដែលប្រជាពុទ្ធសាសនិកត្រូវសមាទានសីលមាននិច្ចសីលហៅថាសីល៥ ឬឧបោសថសីលហៅថាសីល៨ជាដើម,ហើយសមាទានមិនត្រឹមតែអស់លោកពុទ្ធបរិស័ទនៅទីនេះប៉ុណ្ណោះទេ គឺថែមទាំងប្រជាពុទ្ធសាសនិកទាំងឡាយទាំងអស់នៅលើពិភពលោកនេះទាំងមូល ក៏ត្រូវតែសមាទាននៅថ្ងៃនេះដូចគ្នាដែរឲ្យតែជាពុទ្ធសាសនិកហើយការសមាទានសីលនេះទៀតសោតមិនមានរើសវ័យថាចាស់ក្មេងអីទេមិនថាអ្នកមានបណ្ដាសក្តិឥតបណ្ដាសក្តិអ្វីទេ,ឬស្ដេច,មន្ត្រី,សេដ្ឋី,គហបតី,ពាណិជករ,កម្មករ,កសិករអីទេ! ទាំងមិនរើសថាជនជាតិណានគរណាឬទ្វីបណាឡើយផង គឺសមាទានបានទាំងអស់ឲ្យតែមានឆន្ទៈ គឺចិត្តជ្រះថ្លាក្នុងការសមាទាន,ប្រសិនបើបានសមាទានតាំងពីក្មេងទៀតនោះ ក៏រឹតតែប្រសើរណាស់ទៅទៀត! ព្រោះថាប្រសិនបើគិតថាចាំដល់ចាស់សឹមសមាទានសីលនោះ ក្រែងលោរស់នៅមិនបានដល់ចាស់នោះហ្ន៎ា រួចបើស្លាប់ទៅដោយពុំមានសីលនៅក្នុងខ្លួនគឺក្នុងចិត្តផងទេនោះពិតជាមិនបានទៅកើតនៅស្ថានសួគ៌សុគតិភពឡើយ ដូច្នេះបានជាថា សមាទានសីលពីក្មេងទៅវាប្រសើរ!។ ការសមាទានសីលឬការរក្សាសីលនេះបើនិយាយតាមន័យពាក្យខ្មែរយើងឲ្យស្រួលស្ដាប់ទៅគឺថាយើងមកតាំងចិត្តធ្វើអំពើល្អ,ធ្វើសេចក្ដីល្អទេតើ!ធ្វើឲ្យល្អទាំងផ្លូវកាយវាចាចិត្ត, មានមិនសំឡាប់គេឬមិនប្រើគេឲ្យសំឡាប់, មិនលួចទ្រព្យគេឬមិនប្រើគេឲ្យលួចជាដើម ។ បើដូច្នេះមិនសមបើមានអ្នកខ្លះពោលថាៈ "ខ្ញុំមិនទាន់ហ៊ានសមាទានសីលទេពីព្រោះខ្ញុំនៅក្មេង" បើអញ្ចឹងមានតែយើងខ្លាចអំពើល្អឬ?។ សូមលោកអ្នកស្ដាប់ពិចារណាគិតទៅមើល!យើងរក្សាបានប៉ុន្មានថ្ងៃ? ប៉ុន្មានម៉ោង?យើងបានបុណ្យប៉ុណ្ណោះដែរ!ប្រសិនបើដាច់ពេលណាចាំគិតទៀត។ សូមបញ្ជាក់ថា តាមផ្លូវព្រះធម៌ការសមាទានឬការរក្សា

សីលនេះដែលសំខាន់បំផុតនោះនៅត្រង់“ចិត្ត” គឺត្រូវតាំងចិត្តឲ្យល្អឲ្យមូលក្នុងអារម្មណ៍ជាកុសលតែមួយ នៅពេលដែលកំពុងសមាទានគឺកំពុងទទួលសីលហ្នឹងត្រូវប្រុងប្រយត្ន័ស្មារតីឲ្យជាប់តាមវាចារបស់យើងជានិច្ចកុំថាតែមាត់តាមលោកអ្នកឲ្យដូចជាថា ពុទ្ធំ សរណំ គច្ឆាមិ ឬក៏ បាណា អទិន្នា កាមេសុ អញ្ចឹងជាដើម ហើយចិត្តរបស់យើងបែរជាឲ្យអណ្តែតអណ្តូងទៅឯណាឯណីបាត់ទៅនោះ,បើអញ្ចឹងអត់កើតទេ!អត់ទេ! ព្រោះសីលស្ថិតនៅនឹងចិត្តរបស់មនុស្ស!សីលមិនអាចតាំងនៅតែនឹងបបូរមាត់តែម៉្យាងនោះកើតទេ!អត់កើតទេត្រូវយល់ឲ្យច្បាស់អញ្ចឹងព្រះពុទ្ធដីកាបញ្ជាក់ថា : ចេតនាហំ ភិក្ខវេ សីលំ វទាមិ ម្នាលភិក្ខុទាំងឡាយ!តថាគតហៅចេតនាថាជាតួសីល,ហើយលោកខែសេចក្តីតទៅទៀតថា ចេតនា ចេតសិកំ ចិត្តំ ចេតនាវាគ្រាន់តែជាចេតសិករបស់ចិត្តប៉ុណ្ណោះ, គឺចិត្ត! បើចេតនាទទួលសីលមកហើយចិត្តក៏ទទួលរក្សាទុកទៅ។ ចិត្តនិងចេតសិកនេះវាកើតវារលត់តែជាមួយគ្នា!វាស្ថិតនៅតែជាមួយគ្នាហ្នឹងឯង,មិនដែលនៅបែកពីគ្នានោះទេ។នេះនិយាយចំពោះតែលោកអ្នកសប្បុរសណា ដែលមិនទាន់បានយល់នោះទេ បើលោកអ្នកសប្បុរសដែលបានយល់ហើយបានដំកល់ចិត្តស៊ប់មូលក្នុងអារម្មណ៍តែមួយហើយនោះ ជាការប្រពៃណាស់ហើយគឺទទួលសីលមកសីលចូលទៅក្នុងចិត្តផ្ទុកៗតែម្តង!។មួយវិញទៀតខ្ញុំតែងធ្លាប់បានឮមនុស្សខ្លះគេនិយាយថាមានលោកអ្នកខ្លះខ្លួននៅក្មេងទេ!ប៉ុន្តែចង់ធ្វើបុណ្យ“កឋិន” រួចមានអ្នកផ្សេងទៀតនិយាយបែបឃាត់ថា“បើធ្វើ“កឋិន” ពីក្មេងវានាំឲ្យឆាប់ងាប់”។ រឿងបែបនេះ បើតាមយោបល់របស់ខ្ញុំ!ៗយល់ថា អ្នកដែលឃាត់គេមិនឲ្យធ្វើអំពើល្អគឺកឋិននោះឯងទេ គួរតែមានបាបនោះហើយគួរតែខ្លួនឯងអ្នកនិយាយឃាត់គេនោះទេ ដែលអាយុខ្លីនោះ! ។ពីព្រោះក្នុងគម្ពីរព្រះពុទ្ធសាសនាពុំដែលហាមមិនឲ្យធ្វើអំពើល្អគឺបុណ្យកឋិនពីក្មេងទេមានតែសរសើរ,រីឯការសមាទានសីលពីក្មេងក៏មានន័យ

ជាទំនងដូចគ្នានេះដែរ!។ សូមលោកអ្នកស្ដាប់មេត្ដាពិចារណាឲ្យបាន ល្អិតល្អដោយខ្លួនឯងផ្ទាល់តទៅទៀតផង។ឯព្រះធម៌ទេសនាក្នុងពេល នេះ អាត្មាសំដែងអំពី"សីល"ហ្នឹងតែម្ដង! សាធុសប្បុរសទាំងឡាយ!! សីលនេះបុព្វបុរសរបស់យើងលោកបានសមាទានស្ទើរតែគ្រប់គ្នាតាំង ពីយូរលង់ណាស់មកហើយមានសីល៥សីល៨សីល១០ជាដើម,សីល ៥យើងក៏ស្គាល់គ្រប់គ្នាហើយថាមានសិក្ខាបទ៥គឺ:ទី១-បាណាតិបាត ប្រែ:ការហាមមិនឲ្យសម្លាប់គ្នានិងកុំប្រើគេឲ្យសម្លាប់ទាំងសត្វតិរច្ឆាន ផង!។ ទី២-អទិន្នាទាន ការហាមមិនឲ្យលួចគ្នា និងកុំប្រើគេឲ្យលួច។ ទី៣-កាមេសុ មិច្ឆាចារ:ការហាមមិនឲ្យប្រព្រឹត្តខុសក្នុងផ្លូវកាមគុណ។ ទី៤-មុសាវាទា ការហាមមិនឲ្យនិយាយពាក្យភូតកុហកបោកប្រាស់គ្នា ទី៥-សុរាមេរយ: ការហាមមិនឲ្យផឹកទឹកស្រវឹង និងកុំស្រវឹង កុំញៀន នឹងគ្រឿងស្រវឹងនិងគ្រឿងញៀនអ្វីផ្សេងៗទាំងអស់។នៃសីល៥មាន ប៉ុណ្ណឹង។ឯសីល៨ថែមតែ៣សិក្ខាបទគឺវិកាល,នច្ចគី,ឧច្ចា,ពីលើ៥មក ជា៨ទៅហើយ, ឯសីល១០ក៏ដូចគ្នាថែមតែ២សិក្ខាបទគឺមាលាដែល បំបែកចេញពីនច្ចគីមកនិងជាតរូបពីលើ៨មកក៏ជា១០ទៅហើយដែរ! ឯសិក្ខាបទ៥ខាងដើម ទុកនៅដដែល!ព្រោះសិក្ខាបទ៥ខាងដើមនេះ ជាគ្រឹះរបស់សីលទាំងអស់! សូម្បីសីល៤ ដែលមានសិក្ខាបទ២២៧ របស់ពួកភិក្ខុ ក៏ត្រូវតែមានសីល៥នេះជាគ្រឹះដ៏រឹងមាំផងដែរ។ឯសិក្ខា បទទី៣.កាមេសុ ហាមមេថុនធម្មចំពោះតែថ្ងៃសីល(ឧបោសថប៉ុណ្ណោះ) ចំណែក អព្រហ្មចរិយា ហាមមេថុនធម្មគ្រប់ប្រភេទទាំងអស់! ដោយ មានសិក្ខាបទ,វិកាល,នច្ចគី,ឧច្ចា. ជាឱសថ ជួយបន្សាបថាមពល នៃ កាមរាគៈកុំឲ្យវាកំរើកបាន!។ ឥឡូវយើងត្រូវពិចារណា អំពីពាក្យថា: "សីល"នេះ, ឲ្យបានយល់ច្បាស់, យល់ដល់ជម្រៅនៃពាក្យនេះមើល មានន័យយ៉ាងណា?តើសភាវៈអ្វីទៅដែលហៅថាសីល?ស្អីទៅសីល ហ្នុង? តើសីល!មានរូបធ្វើឲ្យយើងចាប់កាន់បង្ហាញគ្នាថា:សីល មាន

ពណ៌លឿងពណ៌ខៀវ អញ្ចឹងជាដើមបានដែរឬទេ ?ចម្លើយថាទេ !ទេ ! ទេ !សីលមិនមានរូបទេ !វាជានាមធម៌,ជាអរូបធម៌,គ្រាន់តែមានឈ្មោះ សម្រាប់ហៅប៉ុណ្ណោះ។បើអញ្ចឹងតើសីលស្ថិតនៅឯណា ?ឆ្លើយៈសីល ស្ថិតនៅនឹងចិត្ត របស់មនុស្ស !ហើយជាចិត្តដ៏ត្រជាក់ ! ទើបសីលអាច ស្ថិតនៅបាន។សីលនេះបណ្ឌិតលោកឲ្យន័យច្រើនយ៉ាងទីខ្លះ,លោក ឲ្យន័យថា“ប្រក្រតី”ទីខ្លះថា“ត្រជាក់”ទីខ្លះថា“ក្បាល,ប្រធាន”ទីខ្លះថា “សភាវៈអប់រំ,កាយ,វាចា,ចិត្តឲ្យមានរបៀបរៀបរយល្អហៅថា“សីល”! និងទីខ្លះទៀតលោកឲ្យន័យថា“ចិត្តមេត្តា”ជាតួសីល ! ឬលោកហៅថា ចេតនា ជាតួសីលក៏បាន,ប៉ុន្តែចេតនាវាជាចេតសិករបស់ចិត្ត !សំរាប់ជំ រុញឬទាញឬទប់ចិត្តតែប៉ុណ្ណោះ,ហើយវាកើតរលត់ជាមួយចិត្ត, វាដេក ត្រាំនៅនឹងចិត្តហ្នឹងឯង !ចុះហេតុដូចម្ដេចបានជាថាចិត្តមេត្តាជាតួសីល ?ចម្លើយៈ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថា“ចិត្តមេត្តា”ជាតួសីលនោះ យើងគប្បីធ្វើការប្រៀបធៀបផ្ទុយបន្តិចវិញថា មនុស្សយើងណាមួយក៏ ដោយនៅលើពិភពលោកទាំងមូលនេះ, បើមិនមានចិត្តមេត្តាទេ ! គឺជា អ្នកមានចិត្តកាចសាហាវឃោរឃៅ,នោះសីលមិនអាចស្ថិតនៅជាមួយ មនុស្សនោះបានទេ ! ពីព្រោះសីល !វាត្រូវស្ថិតនៅនឹងចិត្តរបស់មនុស្ស ហើយដែលជាចិត្តមេត្តាដ៏ត្រជាក់ទៀតផង។ ខ្ញុំលើកឧទាហរណ៍យ៉ាង ខ្លីពីសីល“បាណា”មកបញ្ជាក់ឲ្យច្បាស់ថាៈមនុស្សយើងទាំងអស់ !នៅ លើពិភពលោកទាំងមូលនេះម្នាក់ណាក៏ដោយបើមានចិត្តមេត្តានៅក្នុង ខ្លួនហើយសម្លាប់គេមិនកើតទេ !សូម្បីសត្វតិរច្ឆានក៏ដោយ, បើសម្លាប់ មិនកើតឬមិនហ៊ានសម្លាប់, នែ !ហ្នឹងហើយដែលជាប់ “សីលបាណា” នោះ,គឺចេតនាវៀរចាកការសម្លាប់នោះឯង។ហើយត្រូវយល់ឲ្យច្បាស់ ថាៈសីលទាំងអស់សុទ្ធតែមានចិត្តវៀរចាកជា“សមុដ្ឋាន”ព្រោះចិត្តជា ប្រធានក្នុងរូបកាយមនុស្ស ! ដូចព្រះពុទ្ធដីកាបញ្ជាក់ថា មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា ប៉ុណ្ណោះជាដើមប្រែៈទង្វើអ្វីៗទាំងអស់ល្អ

ក្តីមិនល្អក្តីដែលមនុស្សធ្វើកើតបាន សុទ្ធតែសម្រេចអំពីចិត្តទាំងអស់! គឺមានចិត្តផ្តើមមុនជាដរាប។ដូច្នេះសូមបញ្ជាក់ឲ្យច្បាស់សារជាថ្មីឡើងវិញថាមាន“ចិត្តមេត្តា”ទើបមានសីល។ ប៉ុណ្ណេះជាអត្ថន័យ “សីល”។ តទៅនេះ យើងគប្បីប្រើវិចារណញ្ញាណគឺបញ្ញាដ៏ជ្រាលជ្រៅពិចារណាមួយកំរិតទៀតឲ្យយល់ដល់ចំណុចទឹកព្រះហឫទ័យរបស់ព្រះពុទ្ធដែលព្រះអង្គសំដែងប្រាប់ឲ្យមនុស្សលោកនៅលើពិភពលោកទាំងមូលនេះគោរពប្រតិបត្តិ!សមាទានសីល៥នេះ! តើព្រះអង្គមានព្រះបំណងដូចម្តេច?ត្រង់ចំណុចនេះសាធុសប្បុរសទាំងឡាយបានដឹងច្បាស់ហើយថាៈ អង្គព្រះសម្ពុទ្ធជាព្រះអគ្គមហាបណ្ឌិតដ៏កំពូលលើត្រៃលោក, ឥតមានអ្នកប្រាជ្ញណាមួយត្រឹមស្មើនឹងព្រះអង្គឡើយ! ទ្រង់មានព្រះមហាករុណាដ៏ទូលំទូលាយណាស់! ចំពោះមនុស្សសត្វទូទៅ នៅលើពិភពលោកនេះឥតមានរើសមុខ, ឥតមានរើសជាតិសាសន៍អ្វីឡើយ! ដែលព្រះអង្គចង់ឲ្យមនុស្សកាន់សីល៥គឺ“ចិត្តមេត្តា”នេះដោយព្រះហឫទ័យចង់ឲ្យមនុស្សលោកនៅលើពិភពលោកនេះទាំងមូល បានសេចក្តីសុខទាំងអស់គ្នាតែម្យ៉ាងប៉ុណ្ណោះ គឺឥតមានព្រះទ័យចង់បានកម្រៃអ្វីបន្តិចសោះឡើយហើយបើតាមព្រះពុទ្ធបំណងគឺព្រះអង្គចង់ឲ្យ“មេ”អ្នកដឹកនាំប្រទេសនិមួយៗគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកនេះទាំងមូលមាន“សីល”មុនគេបង្អស់!, ព្រោះអ្វី? ព្រោះថាបើព្រះមហាក្សត្រ, បើប្រធានាធិបតី,បើនាយករដ្ឋមន្ត្រី, មានសីលគឺ ចិត្តមេត្តានៅក្នុងខ្លួនហើយនោះៗ, ឯការងាររដ្ឋទូទៅនឹងមាន“យុត្តិធម៌”!ម្ល៉ោះហើយប្រជាពលរដ្ឋដែលរស់នៅក្រោមអំណាចនោះឯងៗ នឹងបានសេចក្តីសុខដ៏ត្រជាក់ត្រជំពេញមួយនគរ។តាមទស្សនរបស់ពុទ្ធសាសនាបញ្ចសីលាឬសីល៥នេះ ជាគ្រឿងអលង្ការដ៏មានតម្លៃវិសេសបំផុតសម្រាប់ប្រចាំជីវិតរាល់ថ្ងៃរបស់មនុស្សគ្រប់ៗរូប មិនថាជាតិណា,សាសន៍ណា,ឬក៏ប្រទេស,ទ្វីបណាឡើយ។ឲ្យតែជាមនុស្សនៅលើពិភពលោកនេះទាំង

មូលត្រូវតែមានសីល៥នេះឲ្យបានគ្រប់ៗគ្នា! ពីព្រោះសីល៥នេះគឺជា "មនុស្សធម៌"។ = មនុស្សប្រសិនបើមិនមានសីល៥នៅក្នុងខ្លួនទេ!ជាមនុស្សមិនទាន់គ្រប់គ្រាន់ទេ!។ សីល ជាអាទិកល្យាណធម៌ គឺជាធម៌មេកុសលធម៌ទាំងឡាយទាំងពួងមុនដំបូងគេបង្អស់ក្នុងពុទ្ធសាសនា, រួចជាមនុស្សទាំងអស់នៅលើពិភពលោកនេះ គួរឲ្យមានសីលនៅក្នុងខ្លួនគឺក្នុង"ចិត្ត"គ្រប់ៗគ្នាមុនគេដែរ។ សីលនេះ ជាកុសលធម៌ងាយបំពេញជាងកុសលធម៌ដទៃទៀតមាន ទាន ជាដើម ព្រោះកុសលធម៌គឺ ទាន លុះតែមានទេយ្យវត្ថុគ្រប់គ្រាន់ល្មមធ្វើបានផង មានបដិគ្គាហកៈអ្នកទទួលផងហើយមានចេតនាដ៏មុតមាំខ្លាំងក្លាក្នុងការលះធ្វើផងទើបទើបអាចធ្វើកើតជាទានបានហើយមានកិច្ចដែលត្រូវខ្វល់ខ្វាយក៏ច្រើនផងដែរ។ ឯកុសលធម៌គឺសីល មិនដូច្នោះទេ! គឺគ្រាន់តែសិក្សាឲ្យចេះសិក្ខាបទទាំង ៥ ហើយចេះតម ចេះវៀរចាក គ្រប់សិក្ខាបទទាំងអស់, មានចេតនាលះបាបប៉ុណ្ណោះ,ហើយសមាទានទៅបានហើយមិនមានខាតបង់អ្វីច្រើនឡើយ។ ហេតុនេះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថាសីលជាអាទិកល្យាណធម៌ជាធម៌ល្អគួរមានមុនគេបង្អស់ ។ ព្រោះថាជាតិជាមនុស្សទាំងអស់អ្នកដែលមានសីលនៅក្នុងខ្លួនហើយទុកជាគ្រឿងអលង្ការសំរាប់លម្អជីវិតឲ្យស្រស់បំព្រងជានិច្ចរួចប្រសិនបើនរជនណាបានរក្សាគ្រប់សិក្ខាបទទាំង៥នេះ ឲ្យបានជាប់ល្អស្អាតបរិសុទ្ធផូរផង់កុំឲ្យដាច់ធ្លុះធ្លាយសិក្ខាបទណាមួយ,នរជននោះឯងប្រសិនបើចូលទៅកាន់ទីប្រជុំណាមួយតែងមានទឹកមុខប្រកបដោយមន្តស្នេហ៍ហាក់ដូចជាបានបង្កប់នូវស្នាមញញឹមប្រិមប្រិយដ៏ស្រស់បំព្រងនៅនឹងមុខជានិច្ច! អ្នកដែលមានសីលល្អបរិសុទ្ធស្អាតពិតជាអញ្ជឹង។

## <u>សីលមានអត្ថន័យ២យ៉ាង:</u>

អត្ថន័យទី១ជាឧបញ្ញត្តិ,អត្ថន័យទី២ជាឧប្រណិបតន៍។<u>សំនួរ:</u>អត្ថន័យទី១សីលដែលជាឧបញ្ញត្តិនោះតើដូចម្តេច? <u>ចម្លើយ:</u>សីលដែលជា ឧ

បញ្ញត្តិនោះគឺខ ដែលព្រះសម្ពុទ្ធទ្រង់ហាមមិនឲ្យមនុស្សទូទៅនៅលើ ដុំពិភពលោកទាំងមូលនេះ ប្រព្រឹត្តធ្វើ គឺព្រះអង្គឲ្យចៀសវាង ឲ្យលះបង់! ក៏គឺសីល៥នេះឯង! គឺៈ ទី១-បាណា ព្រះពុទ្ធទ្រង់ហាមថាៈ ជាមនុស្សនៅលើពិភពលោកទាំងមូលនេះកុំសម្លាប់មនុស្សដូចគ្នានិងកុំប្រើគេឲ្យសម្លាប់សូម្បីសត្វតិរច្ឆានក៏ដោយ។ទី២-អទិន្នាទាន ព្រះពុទ្ធទ្រង់ហាមថា ជាមនុស្សទាំងអស់!នៅលើពិភពលោកទាំងមូលនេះ កុំលួចគ្នានិងកុំប្រើគេឲ្យលួច!។ ទី៣- កាមេសុ មិច្ឆាចារៈ ព្រះពុទ្ធទ្រង់ហាមថាជាមនុស្សទាំងអស់នៅលើពិភពលោកទាំងមូលនេះទាំងប្រុសទាំងស្រីចូរកុំប្រព្រឹត្តឲ្យខុសក្នុងផ្លូវកាម! នៃត្រង់នេះត្រូវស្តាប់ឱ្យបាន! ព្រះពុទ្ធហាមតែការប្រព្រឹត្តិខុសទេ!។ ទី៤- មុសាវាទ ព្រះពុទ្ធហាមថាជាមនុស្សទាំងអស់!នៅលើពិភពលោកទាំងមូលនេះ កុំនិយាយពាក្យមិនពិត, ពាក្យញុះញង់,ពាក្យអាក្រក់,កុហក បោកប្រាស់គ្នា! ។ ទី៥-សុរាមេរយៈ ព្រះពុទ្ធហាមថាជាមនុស្សទាំងអស់នៅលើពិភពលោកទាំងមូលនេះ កុំផឹកទឹកស្រវឹងកុំស្រវឹងកុំញៀនក្នុងគ្រឿងស្រវឹងគ្រឿងញៀនអ្វីផ្សេងៗទាំងអស់ ។ នេះឯងសីលដែលជា ខបញ្ញត្តិគឺព្រះអង្គបញ្ញត្តិហាមអញ្ចឹង។ <u>សំនួរៈ</u> អត្ថន័យទី២សីលដែលជាខប្រណិបត័ន៍នោះតើដូចម្តេចដែរ? <u>ចម្លើយៈ</u>សីលដែលជាខប្រណិបន៍នោះគឺជាខ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ទូន្មានមនុស្សទូទៅនៅលើដុំពិភពលោកទាំងមូលនេះឲ្យ“ប្តេជ្ញាចិត្ត”ឲ្យគោរពធ្វើតាមក៏នៅក្នុងសីល៥ហ្នឹងដ-ដែលគឺៈទី១-បាណា ព្រះពុទ្ធឲ្យប្តេជ្ញាចិត្តថាខ្ញុំព្រះអង្គឬខ្ញុំព្រះករុណាសូមប្តេជ្ញាចិត្ត ថាមិនសំឡាប់មនុស្សដូចគ្នាអស់មួយជីវិត និងមិនប្រើគេឲ្យសំឡាប់សូម្បីសត្វតិរច្ឆានក៏ដោយ។ ទី២-អទិន្នាទាន ព្រះពុទ្ធឲ្យប្តេជ្ញាចិត្តថា ខ្ញុំព្រះករុណាសូមប្តេជ្ញាចិត្តថាៈ មិនលួចគេ អស់មួយជីវិតនិងមិនប្រើគេឲ្យលួច។ ទី៣-កាមេសុ មិច្ឆាចារៈ ព្រះពុទ្ធឲ្យប្តេជ្ញាចិត្តថាខ្ញុំព្រះករុណាសូមប្តេជ្ញាចិត្តថាៈ មិនប្រព្រឹត្តឲ្យខុសក្នុងផ្លូវកាមអស់មួយ

ជីវិត។ ទី៤-មុសាវាទ ព្រះពុទ្ធឲ្យប្ដេជ្ញាចិត្តថា ខ្ញុំព្រះករុណាសូមប្ដេជ្ញាចិត្តថាមិននិយាយពាក្យមិនពិត-ពាក្យញុះញង់-ពាក្យអាក្រក់ កុហកបោកប្រាស់អស់មួយជីវិត។ ទី៥-សុរាមេរយៈ ព្រះពុទ្ធឲ្យប្ដេជ្ញាចិត្តថា ខ្ញុំព្រះករុណាសូមប្ដេជ្ញាចិត្តថាៈ មិនផឹកទឹកស្រវឹង, មិនស្រវឹង,និងមិនញៀនក្នុងគ្រឿងស្រវឹងគ្រឿងញៀនអ្វីផ្សេងៗទាំងអស់,អស់មួយជីវិតនៃ! នេះហើយ!សីលដែលជា៥ប្រណិបតន៍គឺព្រះពុទ្ធឲ្យប្រណិប័តន៍អញ្ចឹង! រួចត្រង់ពាក្យថាៈ ខ្ញុំព្រះអង្គឬខ្ញុំព្រះករុណា សូមប្ដេជ្ញាចិត្តនេះមិនមែនប្ដេជ្ញាតែមនុស្សម្នាក់ទ!េ គឺសំដៅយកមនុស្សទាំងអស់គ្នានៅលើពិភពលោកទាំងមូលនេះដែលមានឆន្ទៈស្ម័គ្រចិត្តសមាទានសីលហើយនោះម្នាក់ៗត្រូវតែប្ដេជ្ញាចិត្តគ្រប់គ្នារៀងៗខ្លួនដូច្នេះទាំងអស់គ្នាតែម្ដង! ព្រោះថា ប្រសិនបើមនុស្សមួយចំនួន!១ចំហៀងពិភពលោកប្ដេជ្ញា,តែមនុស្ស១ចំនួន១ចំហៀងពិភពលោកទៀតមិនប្ដេជ្ញានោះបើដូច្នោះក៏មិនបានសេចក្ដីសុខទាំងអស់គ្នាដែរ!លុះណាតែមនុស្សទាំងអស់នៅលើពិភពលោកទាំងមូលនេះ ប្ដេជ្ញាចិត្តទាំងអស់គ្នា មិនធ្វើអំពើអាក្រក់ទាំង៥សិក្ខាបទ នេះដល់គ្នានឹងគ្នាទៅវិញទៅមកទាំងអស់គ្នាទើបបានសេចក្ដីសុខទាំងអស់គ្នា!។ រួចបើនិយាយឲ្យដល់ទីបញ្ចប់តែម្ដងទៅថា បញ្ចសីលា ឬសីល៥ នេះជា"មាគ៌ា"ឆ្ពោះទៅរក"សន្តិ-ភាព"ពិតៗ!, ជា"រូបមន្ត"នៃ"សន្តិភាព"ពិតៗ,ប្រសិនបើមនុស្សគ្រប់ជាតិគ្រប់សាសន៍គ្រប់ស្រទាប់វណ្ណៈទាំងអស់នៅលើពិភពលោកនេះទាំងមូលទាំងអស់គ្នាគោរពប្រតិបត្តិតាមកាន់តាមបានទាំងអស់គ្នាគឺមិនសំឡាប់គ្នាមិនលួចគ្នា,និងមិនរំលោភប្ដីប្រពន្ធគ្នា,មិនកុហកបោកប្រាស់គ្នា,មិនផឹកទឹកស្រវឹង, មិនស្រវឹងមិនញៀន នឹងគ្រឿងស្រវឹងឬគ្រឿងញៀនអ្វីផ្សេងៗ, ជាពិសេស! ដែលគ្រោះថ្នាក់បំផុតនោះគឺការស្រវឹង"អំណាច"។ បើមនុស្សគ្រប់គ្នាវៀរបង់បាន! មិនប្រព្រឹត្តបំពាននូវសីលទាំង៥នេះទាំងអស់គ្នា!ទាំងពិភពលោកទាំងមូលទៅ, នោះ

ពិភពលោកនេះទាំងមូលនឹងមានសុខសន្តិភាពពិតៗសុខក្សេមក្សាន្ត, សុខសាន្តត្រាណ,ឥតមានសង្គ្រាមត្រជាក់, សង្គ្រាមក្តៅអ្វីបន្តិចបន្តួចសោះឡើយ!នេះជាសេចក្តីពិត!ជាសច្ចៈធម៌ៗ ចំណុចត្រង់នេះខ្ញុំចង់តែនិយាយថាធ្វើផ្ទះមិនចាំបាច់បិទទ្វារផងក៏បានដែរ!ៗ ជាទីបញ្ចប់! ខ្ញុំបញ្ជាក់អំពី“អត្ថរស”របស់សីលបន្តិចទៀតថាសីលជាធម្មយាននិងជាធម្មរសដ៏ប្រសើរបំផុតសំរាប់ឲ្យសត្តមនុស្សនៅលើពិភពលោកនេះទាំងមូលក្រេបផឹក,ក្រេបផឹកឲ្យមានកម្លាំងសតិបញ្ញាស្មារតីភ្ញាក់រលឹកពិចារណាហើយ អាចលះកាត់កំចាត់បង់នូវ អកុសលមូលទាំងឡាយមានរាគៈលោភៈជាដើម ឲ្យអស់ពីសន្តានចិត្តបាន! ហើយនឹងចរច្ការតាមមាគ៌ាអដ្ឋង្គិកមគ្គ,ផ្លូវប្រកបដោយអង្គ៨ទៅកាន់ត្រើយ សិវង្គាន គឺសន្តិភាពពិតៗយ៉ាងពិតប្រាកដ!ដូចព្រះពុទ្ធដីកាបញ្ជាក់ថាៈ សីលេន និព្វុតឹ យន្តិ : ប្រជាពលលោកនៅលើពិភពលោកនេះ ទាំងមូលដែលនឹងបានទៅដល់ទីរំលត់ទុក្ខគឺព្រះនិព្វានជាបរមសុខនោះក៏ដោយសារសីលនេះឯង!ៗ នែ!ព្រះសម្ពុទ្ធសំដែងច្បាស់អញ្ចឹង! វាពិតជាអញ្ចឹង!

ឥឡូវ!ការសំដែងអំពីពាក្យថា“សីល”បញ្ចប់មួយវគ្គត្រឹមប៉ុណ្ណេះម្តង!ៗ តទៅនេះ សំដែងអំពីសីល៥ដដែលដោយលើកយកសិក្ខាបទនិមួយៗក្នុងសីល៥នោះមកធ្វើអត្ថាធិប្បាយឲ្យអ្នកស្តាប់បានយល់នូវអត្ថន័យចំណុចសេចក្តីនៃសិក្ខាបទនោះៗ ឲ្យបានច្បាស់លាស់ដូចតទៅៈ <u>សិក្ខាបទទី១គឺសីល បាណា</u>“ការហាមមិនឲ្យសម្លាប់និងកុំប្រើគេឲ្យសម្លាប់” សិក្ខាបទនេះព្រះពុទ្ធមិនមែនហាមមិនឲ្យសម្លាប់ត្រឹម ស្រមោចសង្ការ, មាន់,ទា,ជ្រូក,គោ,ជាដើមនោះទេព្រោះការសម្លាប់ទាំងនេះវាមិនដែលមានប្រតិកម្មអ្វីពីសត្វទាំអស់នោះទេ តែមិនមែនមានន័យថាឲ្យសម្លាប់សត្វទាំងអស់នោះដែរ!សីលបាណានេះបើតាមព្រះពុទ្ធបំណងព្រះអង្គហាមមនុស្សម្នា ទាំងអស់គ្នានៅលើដុំពិភពលោកនេះទាំងមូល មិនឲ្យសម្លាប់មនុស្សដូចគ្នាតែម្តង! ព្រោះមានព្រះពុទ្ធដីកាបញ្ជាក់ច្បាស់ថា :

“ យោ បន ភិក្ខុ សញ្ចិច្ចមនុស្សវិគ្គហំ ជីវិតា វោ រោបេតិ អសមណោ ហោតិ អសក្យបុត្តិយោ ភិក្ខុណាមួយ ក្លែងសម្លាប់សត្វមានរាងកាយជាមនុស្សឲ្យផុតចាកជីវិត ភិក្ខុនោះមិនមែនជាសមណៈមិនមែនជាសក្យបុត្តឡើយគឺថាមិនមែនជាកូន,ចៅរបស់តថាគតទេ”នែ!ព្រះពុទ្ធបញ្ជាក់ច្បាស់អញ្ចឹង,ច្បាស់ថាម៉េច? ថា“សត្វមានរាងកាយជាមនុស្ស” រួចបើមានរាងកាយជាមនុស្សហើយគឺមនុស្សហ្នឹងឯងតែម្តង។សូម្បីប្រទេសទាំងអស់នៅលើពិភពលោកនេះទាំងមូលសុទ្ធតែមានច្បាប់មានមាត្រាស្តីពីការត្រូវគោរពសិទ្ធិនិងការពារសិទ្ធិមនុស្សដូចៗគ្នាទាំងអស់ គឺមិនឲ្យមានការរំលោភលើគ្នា បៀតបៀនគ្នា ជិះជាន់សង្កិតសង្កន់គ្នាដោយមធ្យោបាយតាមរូបភាពណាមួយក៏ដោយពិសេសបំផុតគឺការហាមមិនឲ្យមានដល់ការសម្លាប់គ្នាហ្នឹងឯងតែម្តង!ព្រោះថាៈ=ជាមនុស្សសុទ្ធតែមាន សិទ្ធិ ស្មើគ្នាក្នុងការរស់នៅ!តាំងពីកំណើតមកម្ល៉េះ! = ជាមនុស្សមាន សិទ្ធិ ស្រឡាញ់ជីវិតដូចគ្នាទាំងអស់គ្នា,សូម្បីសត្វតិរច្ឆានក៏វាចេះស្រឡាញ់ជីវិតរបស់វាដែរ។ =ជាមនុស្សមានសិទ្ធិចង់មានជីវិតរស់នៅដូចគ្នាទាំងអស់គ្នា!។ដូច្នេះជាមនុស្សមិនគួរសម្លាប់មនុស្សដូចគ្នាទេ។ព្រោះវាអាក្រក់មើលណាស់,វាជាអំពើបាបៗខ្លាំងណាស់!វានាំឲ្យមានកម្មពៀរវេរានឹងគ្នាធំធេងណាស់វាខុសនឹងច្បាប់ធម្មជាតិធ្ងន់ធ្ងរណាស់មនុស្សសូម្បីសម្លាប់គ្នាម្នាក់ទល់នឹងម្នាក់ ក៏វាអាក្រក់ណាស់ទៅហើយចុះទំរាំដល់បើមានការសម្លាប់គ្នារាប់រយ,រាប់ពាន់នាក់ (ដោយសង្គ្រាម) ទៀតនោះ,តើវានឹងជាមហាអាក្រក់,មហាវិនាសកម្ម,មហាសោកនាដ-កម្ម,មហាហិនហោចខ្លោចផ្សា,ដល់កំរិតណាទៅ?។ ប្រសិនបើមាន កត្តា អ្វីដែលចៀសមិនរួចនាំឲ្យមានការសម្លាប់គ្នាទៅវិញទៅមកនោះក៏ព្រោះតែមកពីមេដឹកនាំនោះៗមិនមានសីលគឺចិត្តមេត្តា នៅក្នុងខ្លួននោះឯង ឬបើមានសីលដែរ, តែមានភាគីម្ខាងណានោះ ប្រព្រឹត្តអំពើអយុត្តិធម៌រំ-លោភបំពានមកលើភាគីម្ខាងទៀតយ៉ាងពិតប្រាកដរហូត

ដល់គេអត់ទ្រាំមិនបាន។សិក្ខាបទទី១បាណានេះមានឥទ្ធិពលខ្លាំងក្លាណាស់ ព្រោះហេតុថាប្រសិនបើប្រជាពលលោកនៅលើដុំពិភពលោកនេះទាំងមូល,មិនស្តាប់ព្រះពុទ្ធហើយនាំគ្នាធ្វើបំពានលើសិក្ខាបទទី១បាណានេះមានការកាប់សម្លាប់គ្នាដោយផ្ទាល់ក្តីបាញ់ប្រហារគ្នាដោយអាវុធប្រយោលក្តី ឬក៏ឈានដល់ប្រើឧបករណ៍បាណាតិបាតដ៏ទំនើបៗដ៏ប្រល័យ,ដូចជា"នុយក្លេអ៊ែរ,បរមាណូ"ជាដើមក្តី តែ១គ្រាប់,ប៉ុណ្ណោះតើមហាវិនាសកម្ម,មហាសោកនាដកម្ម,មហាហិនហោចខ្លោចផ្សានឹងឡើងដល់កំរិតណាទៅ?សូមលោកអ្នកស្តាប់ពិចារណាបន្តិចទៅមើលថា:នៅលើដុំពិភពលោកយើងនេះបច្ចុប្បន្នហ្នឹងសព្វថ្ងៃហ្នឹង នៅកន្លែងណាដែលមានការសម្លាប់គ្នាដូចជានៅ"អ៊ីរ៉ាក់"ជាដើមតើវាមានវិនាស-កម្មយ៉ាងណា? មានសោកនាដកម្មដល់កំរឹតណា!? ព្រោះហេតុនោះហើយ បានជាព្រះពុទ្ធហាមមនុស្សមិនឲ្យសម្លាប់មនុស្សដូចគ្នានោះ!! ព្រោះវាមានបាបខ្លាំងក្លាណាស់!មាន"កម្មពៀរវេរា"ធំធេងណាស់! វាខុសនឹងច្បាប់ធម្មជាតិធ្ងន់ធ្ងរណាស់!ដោយអ្នកដែលទទួលរងការឈឺចាប់នោះមិនព្រមនៅស្ងៀមទេ!។ ព្រះពុទ្ធទ្រង់ជ្រាបពីហេតុផលនេះច្បាស់លាស់ណាស់!បានជាព្រះអង្គទូន្មានថាជាមនុស្សនៅលើពិភពលោកនេះទាំងមូល កុំសម្លាប់មនុស្សដូចគ្នា! និងកុំប្រើគេឲ្យសំឡាប់! សូម្បីសត្វតិរច្ឆានក៏មិនគួរសំឡាប់ដែរ!។ រីឯទោស អនន្តរិយកម្ម ក៏មាននៅក្នុងសិក្ខាបទទី១បាណានេះដែរ ហេតុដូច្នេះបានថាសិក្ខាបទទី១បាណានេះមានឥទ្ធិពលខ្លាំងក្លានោះ!។ សិក្ខាបទទី២គឺ សីលអទិន្នាទាន"ដើម្បីបានសេចក្តីសុខទាំងអស់គ្នា"ព្រះពុទ្ធទ្រង់ទូន្មានថាជាមនុស្សទាំងអស់នៅលើពិភពលោកនេះទាំងមូល, កុំលួចគ្នា,និងកុំប្រើគេឲ្យលួច។ មនុស្សយើងទាំងអស់គ្នា,ដើម្បីចិញ្ចឹមជីវិតឲ្យរស់នៅបានត្រូវតែស្វែងរកទ្រព្យសម្បត្តិគ្រប់ៗគ្នាទាំងអស់! គ្រាន់តែមានមុខរបរផ្សេងៗគ្នាប៉ុណ្ណោះ ទៅតាមជំនាញរៀងៗខ្លួន ខ្លះប្រកបមុខរបរជា

កសិកម្ម ខ្លះជាពាណិជ្ជកម្ម ខ្លះជាឧស្សាហកម្មជាដើម,ហើយដើម្បីឲ្យមានជោគជ័យក្នុងការរស់នៅដោយការស្វែងរកទ្រព្យសម្បត្តិនេះ,ព្រះពុទ្ធទ្រង់ចង្អុលបង្ហាញនូវមាគ៌ាដ៏ប្រសើរ៤យ៉ាង ហៅថា ទិដ្ឋធម្មិកត្ថៈប្រយោជន៍សម្រាប់បច្ចុប្បន្នៈ ទី១-ឧដ្ឋានសម្បទា ជាមនុស្ស!ព្រះពុទ្ធទ្រង់ទូន្មានថា, ត្រូវខំប្រឹងធ្វើការងារគ្រប់ជំពូកឲ្យអស់ពីសមត្ថភាព កុំខ្ជិលច្រអូស,កុំស្ពឹកស្រពន់,កុំទំរន់បណ្តោយឲ្យពេលវេលាវាកន្លងទៅដោយឥតប្រយោជន៍,ធ្វើការដើម្បីបានកម្រៃអំពីការងារនោះ!ៗមកជាលុយកាក់ក្តី,ជាវត្ថុអ្វីផ្សេងៗក្តី,ប្រមូលទុកដាក់ដើម្បីផ្គត់ផ្គង់នូវជីវភាពហើយក្នុងកិច្ចប្រកបមុខរបរទាំងនោះព្រះពុទ្ធទ្រង់ទូន្មានថាត្រូវប្រកាន់ខ្ជាប់នូវអំពើសុចរិតសច្ចៈយុត្តិធម៌ជានិច្ច,ទាំងផ្លូវកាយវាចា, និងចិត្តធ្វើយ៉ាងណា! ឲ្យបានទ្រព្យសម្បត្តិមកខ្លួនយើងផង,ហើយកុំឲ្យប៉ះពាល់ដល់សិទ្ធិឬខូចប្រយោជន៍របស់អ្នកដទៃផង!,ធ្វើបានយ៉ាងនេះទើបជាការល្អប្រសើរ។ ទី២-អារក្ខសម្បទា ទាំងអស់គ្នា!រកទ្រព្យសម្បត្តិបានមកហើយ ព្រះពុទ្ធទូន្មានថាត្រូវចេះថែទាំសន្សំសំចៃ!លៃលកទុកដាក់ឲ្យបានគង់វង់ កុំឲ្យបាត់បង់ទៅវិញដោយមិនសមហេតុ មិនសមផល! ទី៣-កល្យាណមិត្តតា ទាំងអស់គ្នា! ត្រូវចេះទំនាក់ទំនងការងារអ្វីគ្រប់ជំពូកជាតែមួយអតិថិជនជាកល្យាណមិត្ត គឺសេពគប់រាប់រកតែជាមួយមនុស្សណាដែលមានចិត្តស្មោះត្រង់ជាមួយគ្នាទៅវិញទៅមកចេះយល់អធ្យាស្រ័យគ្នា ចេះដឹងជួយទុក្ខធុរៈគ្នាចេះជួយផ្តល់យោបល់ល្អៗដល់គ្នាពោលតែពាក្យមានប្រយោជន៍ទាំងអស់គ្នា!ទី៤-សមជីវិតា រកទ្រព្យសម្បត្តិបានមកហើយ ទោះមានដល់កំរិតណាក៏ដោយ! ជាមហាសេដ្ឋីក៏ដោយ ព្រះពុទ្ធទ្រង់ទូន្មានថាត្រូវរៀនរស់នៅយ៉ាងសាមញ្ញ!ឲ្យបានកុំប្រកាន់អស្មិមានៈឲ្យសោះ! កុំប្រកាន់ថា“អញជាអ្នកមានជាងគេ!មានតែអញទេ! គ្មានអ្នកណាស្មើនិងអញទេ!” ដូច្នេះ,ជាដើម,គឺត្រូវរស់នៅតាមបែបមនុស្សមានមនុស្សធម៌!ដ៏ល្អប្រសើរ! ហើយគប្បីធ្វើខ្លួនឲ្យជា

ម្ចាស់លើទ្រព្យសម្បត្តិ, កុំឲ្យទ្រពសម្បត្តិធ្វើជាម្ចាស់លើខ្លួនយើងវិញ ព្រោះវាជាគ្រោះថ្នាក់ធំធេងណាស់, ឆ្លងកាត់រូបមន្តសម្រាប់ស្វែងរកទ្រព្យសម្បិត្តទាំង៤យ៉ាងដែលព្រះសម្ពុទ្ធទ្រង់ទូន្មានមកនេះឃើញថាទ្រព្យសម្បិត្តសុទ្ធតែបានមកដោយការខិតខំប្រឹងព្យាយាមពុះពារគ្រប់ឧបស័គ្គទាំងឡាយដោយកម្លាំងកាយ គឺជាញើសឈាមរបស់មនុស្សយើងសុទ្ធសាធ,មិនមែនបានមកដោយ"អាទិទេព"ណា ជបឲ្យយើងឡើយ!។ ដូច្នេះ បានជាព្រះពុទ្ធទ្រង់ទូន្មានថា ដើម្បីបានសេចក្តីសុខទាំងអស់គ្នា!ជាមនុស្សទាំងអស់នៅលើដុំពិភពលោកនេះទាំងមូលកុំលួចគ្នា!និងកុំប្រើគេឲ្យលួច!។ ឯការលួចនេះទៀតសោត ប្រសិនបើលួចគ្នាតិចតួចក្នុងស្រុកជាទ្រព្យសម្បត្តិធម្មតានោះបញ្ហាក៏តិចតួចដែរ តែបើមានការលួចគ្នាជាផែនទឹកផែនដីគឺលួចបង្ខិតគោលសីមារ រវាងប្រទេសមួយទៅប្រទេសមួយទៀតនោះៗ បញ្ហាវាមានធំធេងណាស់! ធំរហូតដល់ឲ្យមានជាសង្គ្រាមវិនាសកម្មផងទៀតក៏មាន។ ដូច្នេះបានជាព្រះពុទ្ធទ្រង់ទូន្មានថាជាមនុស្សនៅលើពិភពលោកនេះទាំងមូលកុំលួចគ្នានិងកុំប្រើគេឲ្យលួច។ <u>សិក្ខាបទ៣សីល កាមេ</u>"ដើម្បីមានសិទ្ធិ-សេរីភាពមានសុខភាពបរិបូណ៌និងមានសេចក្តីសុខទាំងអស់គ្នា" ព្រះពុទ្ធទ្រង់ទូន្មានថាជាមនុស្សទាំងអស់នៅលើពិភពលោកនេះទាំងមូលទាំងប្រុសទាំងស្រី,ចូរកុំប្រព្រឹត្តឲ្យខុសក្នុងផ្លូវកាម!។សីល កាមេ នេះមានអត្ថន័យទាំងស្រុងសង្កត់ធ្ងន់ទៅលើសង្គមគ្រួសារ,ប្រពៃណីរបស់មនុស្ស,ព្រោះហេតុនោះ ព្រះពុទ្ធមិនបានហាមដាច់ខាតទេ!នូវ "ចរន្ត" ប្រពៃណីរបស់មនុស្សលោក,រវាងស្វាមី-ភរិយាប្តី១,ប្រពន្ធ១, តាមការស្ម័គ្រចិត្តព្រមព្រៀងគ្នាជាគូជីវិតនោះព្រោះវាជារឿងធម្មតាក្នុងផ្លូវមនោសញ្ចេតនារបស់មនុស្សលោកទៅហើយ! តែ!ដែលព្រះពុទ្ធទ្រង់ហាមហើយព្រះអង្គឲ្យចៀសវាងនោះ គឺការប្រព្រឹត្តខុស។ កាមេ នេះវាមានឥទ្ធិពលធំធេងណាស់ព្រោះវាជាតួ"តណ្ហា",តណ្ហាជាមេបញ្ហាដ៏មហិមា

ព្រោះវាជាអកុសលមូលៗ ប្រែថាៈមេបាបគ្រប់យ៉ាង!មនុស្សដែលវិល
កើតវិលស្លាប់ក្នុងសង្សារវដ្តនេះមិនចេះចប់ ក៏ព្រោះតែតណ្ហានេះឯង!
ជួនកាលវិលហួសពីសង្សាររបស់មនុស្ស! រហូតទៅដល់ នរក ប្រេត
តិរច្ឆាន ទៀតផងក៏មាន ព្រោះព្រះពុទ្ធពោលថា នត្ថិ តណ្ហា សមា នទី
ទឹកស្ទឹង ទន្លេ! ដែលហូរពោរពេញខ្នុលខ្មាញ់យ៉ាងណា, ក៏មិនស្មើនឹង
តណ្ហារបស់មនុស្សលោកដែរ!ៗ ហើយបើក្នុងអរិយសច្ចៈ!តណ្ហានេះ
លោកពោលថាជា មេ នាំឲ្យកើត ទុក្ខ!ៗ កាមតណ្ហានេះវាជាបណ្តាញ
កិលេសម្យ៉ាងមានឥទ្ធិពលខ្លាំងក្លាណាស់សម្រាប់ជំរុញលោភៈទោសៈ
មោហៈ ដែលជាឫសគល់នៃអកុសលទាំងឡាយឲ្យកើតឡើង! គ្មានទី
បញ្ចប់,បើវាគ្របសង្កត់លើមនុស្សណាហើយវាធ្វើមនុស្សនោះឲ្យហ៊ាន
ប្រព្រឹត្តខុសមិនត្រឹមតែខុសក្នុងផ្លូវកាមគុណប៉ុណ្ណោះទេ គឺថែមទាំងឲ្យ
ហ៊ានប្រព្រឹត្តខុសក្នុងផ្លូវផ្សេងៗទៀតបានផងៗកាមេ ដែលគេប្រព្រឹត្ត
ខុសនោះ វាមានថាមពលខ្លាំងក្លាណាស់,ប្រសិនបើមនុស្សរកវិធីអ្វីទប់
ស្កាត់មិនបានទេថាមពលរបស់វាខ្លាំងជាង ថាមពល"បរមាណូ"ទៀត,
ព្រោះអ្វី? ពីព្រោះថាមពលបរមាណូ នៅពេលបច្ចុប្បន្ននេះ មានមហា
អំណាចខ្លះគេរកវិធីផ្សំទប់ទល់បាន, រីឯថាមពលរបស់តណ្ហា ដែលគេ
ប្រព្រឹត្តខុសក្នុងផ្លូវកាមនេះប្រសិនបើបណ្តាលឲ្យកើតជា រោគអ្វីម្យ៉ាង
នោះហើយ(អេដស៍)វេជ្ជបណ្ឌិតទាំងឡាយនៅលើពិភពលោកនេះបាន
សារភាពហើយថារកវិធីអ្វីផ្សំថ្នាំព្យាបាលមិនបានទេ! រួចរោគនោះវាក៏
អាចធ្វើអ្នកប្រព្រឹត្តខុសនោះ ឲ្យស្លាប់យ៉ាងទាន់ហន់បំផុតផង!គឺថាបើ
អ្នកណាដែលកើតរោគនេះហើយ!ដេករង់ចាំតែថ្ងៃក្សិណក្ស័យជីវ៉ា តែ
ប៉ុណ្ណោះៗ ដូចជានៅពេលបច្ចុប្បន្ននេះអស់លោកអ្នកស្តាប់ធ្លាប់បាន
ដឹងបានឮ បានឃើញស្រាប់ហើយថាៈ ពួកមនុស្សដែលមិនស្តាប់ព្រះ
ពុទ្ធ,មិនជឿព្រះពុទ្ធ,និងមិនគោរពតាមធម៌របស់ព្រះពុទ្ធ,ដែលព្រះអង្គ
ទូន្មានថាៈកុំប្រព្រឹត្តឲ្យខុសក្នុងផ្លូវកាមនោះ រួចគេបានប្រព្រឹត្តខុសខ្លួន

គេហើយដោះស្រាយមិនរួច នាំគ្នាភ័យសស្លន់សស្លោពេញទាំងពិភព
លោកសព្វថ្ងៃហ្នឹងហើយមានអ្នកខ្លះអង្វរសាវ័ករបស់ព្រះពុទ្ធគឺលោក
សង្ឃខ្លះឲ្យជួយឃោសនាឲ្យពួកខ្លួន នូវរឿងបែបនេះទៀតផង,ធ្វើឲ្យ
លោកសង្ឃច្របូកច្របល់ជាមួយតើវាបានប្រយោជន៍អ្វីទៅបើខ្លួនឯង
មិនស្តាប់ព្រះពុទ្ធរួចប្រព្រឹត្តខុសខ្លួនឯងហ្នុង!!។ សាធុ! សប្បុរសទាំង
ឡាយ! ទោសទុក្ខនិងក្តីអន្តរាយដែលកើតឡើងពីការប្រព្រឹត្តិខុសក្នុង
ផ្លូវកាមេនេះគួរឲ្យភ័យខ្លាចគួរឲ្យតក់ស្លុតណាស់ព្រោះរោគនោះវាកាច
សាហាវខ្លាំងណាស់ហើយមនុស្សដែលស្លាប់ពីរឿងនេះមិនតិចទេសព្វ
ថ្ងៃហ្នឹង!។ ដូច្នេះអស់លោកទាំងឡាយដែល បានដឹងឮហើយគួរនាំគ្នា
ពិចារណាឲ្យបានល្អិតល្អន់ហើយគួរនាំគ្នាប្រព្រឹត្តតាមព្រះពុទ្ធទាំងអស់
គ្នាទៅដែលព្រះអង្គទូន្មានថាទាំងប្រុសទាំងស្រីចូរកុំប្រព្រឹត្តឲ្យខុសក្នុង
ផ្លូវកាមនោះ!។ <u>សិក្ខាបទ៤សីល មុសាវាទ</u> មុសាវាទនេះមិននិយាយ
ដល់វចីកម្មទាំង៤ៈ បិសុណាវាទ,ផរុសវាទ,និងសម្ផប្បលាបៈផងទេ!គឺ
និយាយត្រឹមតែមុសាវាទមួយប៉ុណ្ណោះ!, មុសាវាទនេះ មានរូបមន្តថា :
“ដើម្បីរក្សាមិត្តភាពរក្សាសេចក្តីស្រឡាញ់រាប់អានគ្នាឲ្យបានយូរអង្វែង
ព្រះពុទ្ធទ្រង់ទូន្មានថាៈ! ជាមនុស្សនៅលើពិភពលោកនេះ ទាំងមូលកុំ
និយាយពាក្យមិនពិតពាក្យញុះញង់,បំបែកបំបាក់,អាក្រក់កុហក,បោក
ប្រាស់គ្នា!គួរនិយាយតែពាក្យពិត! ព្រោះពាក្យពិតតែងជាទីស្រឡាញ់
រាប់អាននៃមនុស្សទូទៅផងនៃអ្នកប្រាជ្ញរាជបណ្ឌិតទាំងឡាយផង និង
រហូតដល់ទេវតា,ឥន្ទ្រ,ព្រហ្មផង!។ បានជាព្រះពុទ្ធហាមមិនឲ្យនិយាយ
ពាក្យកុហក ព្រោះពាក្យកុហកជាពាក្យអាក្រក់អកុសល វាធ្វើមនុស្សឲ្យ
ប្រេះឆាបែកបាក់សាមគ្គីគ្នា ឲ្យមនុស្សស្អប់ខ្ពើមគ្នា ឲ្យមនុស្សលែងទុក
ចិត្តគ្នា ធ្វើមនុស្សឲ្យមើលមុខគ្នាមិនត្រង់, មនុស្សសុចរិត ដែលធ្លាប់តែ
និយាយពាក្យពិតសច្ចៈប្រសិនបើត្រូវគេនិយាយកុហកនោះពិតជាអាក់
អន់ចិត្តខ្លាំងណាស់!រួចមិនចង់និយាយរកអ្នកកុហកនោះស្ទើរអស់មួយ

ជីវិតផង, មនុស្សដែលនិយាយពាក្យកុហកអាក្រក់មិនស្មើ និងមនុស្ស ដែលនិយាយពាក្យបោកប្រាស់ទៀត, ព្រោះមនុស្សអ្នកនិយាយពាក្យ បោកប្រាស់,សុទ្ធតែប្រើល្បិចអាក្រក់ពីសពុលបំផុតគឺមានចេតនាចង់ ឲ្យគេវិនាសអន្តរាយដើម្បីអាត្មាខ្លួន។ ឯពួកមនុស្សបោកប្រាស់គេនេះ មានល្បិចខ្ពស់ណាស់!ក្នុងការនិយាយបោកបញ្ឆោតល្បួងលួងលោម ដើម្បីឲ្យអ្នកដែលមិនបានពិចារណាបាក់ចិត្តជឿស្លុងតាមពួកគេបាន ដោយងាយ, ក្នុងសម័យកុំព្យូទ័រនេះពួកនេះហ៊ានទាំងរៀបចំតែងតាំង ធ្វើជាសមាគមបោកប្រាស់ទៀតផង រីឯអ្នកស្លូតត្រង់មិនដឹងល្បិចពួក គេទេ! កាលណាគេបោកប្រាស់បានកម្រៃច្រើនហើយ គេក៏ភៀសខ្លួន ចេញពីកន្លែងនោះបាត់ ឬ ក៏ចេញចោលប្រទេសផងក៏មាន, (ពួកនេះ ច្រើនមានទីតាំងមិនប្រាកដ)ពួកអ្នកបោកប្រាស់ថ្នាក់ខ្ពស់នេះទៅលក់ ដូចលក់វត្ថុអ្វីផ្សេងៗក៏មានដែរ(មាននៅដំបន់ខ្លះនៃប្រទេសខ្លះ)ឯអ្នកដែល ត្រូវគេបោកប្រាស់សុទ្ធតែត្រូវទទួលរងនូវការខកខូចចិត្តខាតបង់ទ្រព្យ សម្បត្តិនិងមានវិប្បដិសារីអស់មួយជីវិតតែប៉ុណ្ណោះ។ ព្រឹត្តិការណ៍បែប នេះប្រសិនបើកើតមានយូរៗទៅ! មនុស្សអាចមានរហូតដល់ហ៊ានសំ-ឡាប់គ្នាផងក៏សឹងមាន, ប៉ុន្តែបុរាណបណ្ឌិតបានពោលថាៈ“ គេបណ្ដុះ ដាំពូជបែបណា? គេតែងបានផលផ្លែផ្កាបែបនោះ ឬក៏ពាក្យភូតច្រើន ចាញ់អាត្មា”។ ឯមនុស្សអ្នកនិយាយពាក្យភូតភរកុហកនេះ ជួនកាល បណ្ដាលឲ្យកើតជាទោសឲ្យផលជាបាប ជាក់ស្ដែងទាន់ភ្នែកភ្លាមៗក៏ មាន។ ដូចមានរឿងព្រេងមួយនិទានថាៈ ក្នុងកាលកន្លងយូរលង់ទៅ ហើយ មានមនុស្សអ្នកនិយាយពាក្យកុហកម្នាក់ បានចូលទៅរកអុស ក្នុងព្រៃដ៏ធំមួយជាមួយអ្នកស្រុកជាច្រើនគ្នា លុះចូលដល់ទៅក្នុងព្រៃ ជ្រៅក៏ស្រែកកុហកលេងថា“នែវ៉ឺយ!គ្នាយើងជួយខ្ញុំផង!មានសត្វខ្លាធំ ណាស់!ៗ”ដល់អ្នកស្រុកគេស្រែកឆោឡោឡើងរត់ទៅជួយ, ស្រាប់តែ បុរសនោះសើចលេងសប្បាយទៅវិញ ។ លុះពេលជាបន្ទាប់មកទៀត

បុរសនោះបានជួបនឹងខ្លាមែន,ក៏ស្រែកឲ្យគេជួយដូចមុនទៀតប៉ុន្តែអ្នកស្រុកគេប្រាប់គ្នាថានែ!"កុំទៅជឿវាអីវានោះនិយាយកុហកទេ"លុះមិនមានអ្នកស្រុកគេទៅជួយ,ខ្លាក៏បានទះបកស្បែកក្បាលបុរសនោះ ស្ទើរក្ស័យជីវិតទៅ។ អាស្រ័យហេតុ-ផលដូចបានជំរាបជូនមកនេះ ជាការសបញ្ជាក់ចំពោះពុទ្ធដីកាដែលព្រះអង្គទ្រង់ទូន្មានថាជាមនុស្សនៅលើពិភពលោកនេះទាំងមូល កុំនិយាយពាក្យកុហកអាក្រក់បោកប្រាស់គ្នាព្រោះវាជាមូលហេតុនៃទុក្ខ។ <u>សិក្ខាបទទី៥គឺសីល សុរាមេរយៈ</u>"ដើម្បីមានឧត្តមគតិល្អ មានបញ្ញាស្មារតីផូរផង់ និងមានសុខភាពបរិបូណ៌" ព្រះពុទ្ធទ្រង់ទូន្មានថាជាមនុស្សនៅលើពិភពលោកនេះទាំងមូលកុំផឹកទឹកស្រវឹងនិងកុំស្រវឹង!កុំញៀននឹងគ្រឿងស្រវឹងគ្រឿងញៀនអ្វីផ្សេងៗទាំងអស់។សីលសុរានេះ បើពោលតាមន័យអត្ថានុរូបគឺន័យត្រង់ស្រានេះបើមនុស្សណាផឹកចូលទៅក្នុងពោះហើយធ្វើមនុស្សនោះឲ្យស្រវឹងមានអារម្មណ៍និងអាការៈក្លៀវក្លា,ក្លាហានជាងប្រក្រតីឬបើផឹកតែបន្តិចបន្តួចធ្វើឲ្យមនុស្សបរិភោគអាហារមានរសជាតិឆ្ងាញ់ដែរ,តែបើមនុស្សណាផឹកច្រើនពេកទៅវានាំឲ្យស្រវឹងខ្លាំង មានចិត្តព្រហើនក៏អាចហ៊ានប្រព្រឹត្តអំពើអាក្រក់ផ្សេងៗគ្រប់យ៉ាងបានដោយងាយ បើមនុស្សនោះមិនមានមនុស្សធម៌ផងបើស្រវឹងហើយ,អាចហ៊ានប្រព្រឹត្តធ្វើអំពើដែលជាព្រហ្មទ័ណ្ឌកំរឹតធ្ងន់ផង,ឬក៏ដល់ថ្នាក់ឧក្រឹដ្ឋផងក៏មាន,រួចប្រសិនបើមនុស្សនោះផឹកហួសកំរឹតទៅទៀត ជាតិស្រានេះវាអាចធ្វើឲ្យខូចសុខភាពរហូតដល់ធ្វើមនុស្សនោះឲ្យខូចសតិអារម្មណ៍ទៅជាវិកលចរិតផងក៏មានដែរ!មនុស្សបើផឹកស្រាជាប់ជានិច្ច ច្រើនតែភ្លេចភ្លាំងស្មារតីភ្លេចអស់នូវភាពជាមនុស្សថ្លៃថ្នូរ ជួនកាលធ្វើឲ្យខ្លួនអ្នកផឹកនោះ ថោកទាបថែមទៀតផង ធ្វើឲ្យខាតបង់ទ្រព្យសម្បត្តិនិងខូចប្រយោជន៍គ្រប់យ៉ាងធ្វើឲ្យមានអាយុខ្លីទៅទៀតផងឯណោះ! ប៉ុន្តែបើផឹកគ្រាន់តែ ដើម្បីសំរួលសុខភាពនោះ, វាជារឿងម្យ៉ាង, រួចបើប្រើត្រាំជាថ្នាំកែរោគទៅវិញ

នោះវាក៏ជារឿងម្យ៉ាងទៅទៀត,បើប្រទេសណាដែលមានអាកាសធាតុត្រជាក់ខ្លាំងហើយគេផឹក ដើម្បីទប់ទល់នឹងធាតុអាកាសត្រជាក់នោះ នោះក៏ជាការម្យ៉ាងរបស់គេទៅទៀត,ប៉ុន្តែនេះនិយាយតាមផ្លូវព្រះសូត្រទ្រមិននិយាយតាមផ្លូវព្រះវិន័យទេ! សីលសុរានេះបើពោលតាមន័យអត្ថប្បដិរូប គឺន័យប្រៀបធៀបវិញនោះ, ការស្រវឹងនេះមានន័យច្រើនបែបទៀត គឺស្រវឹងដោយវ័យ ស្រវឹងដោយ ទ្រព្យសម្បត្តិ ស្រវឹងដោយយសសក្តិនិងស្រវឹង"អំណាច"។ ឯការស្រវឹងក្នុងន័យអត្ថប្បដិរូបខាងក្រោយនេះ,ប្រសិនបើមនុស្សណាស្រវឹងហើយជាការស្រវឹងមានគ្រោះថ្នាក់ធំធេងណាស់!ខ្ញុំសុំមិនធ្វើអត្ថាធិប្បាយទាំងអស់ទេ គឺលើកយកតែការស្រវឹង"អំណាច"មួយមកជំរាបបញ្ជាក់ជូន ដើម្បីឲ្យឃើញច្បាស់ពីការស្រវឹងដែលនាំឲ្យមានគ្រោះថ្នាក់ធំធេងនោះ ដូចតទៅ! និយាយឲ្យឃើញជាក់ស្តែងតែម្តងនៅស្រុកខ្មែរយើងកាលពីឆ្នាំគ.ស.១៩៧៥ដល់១៩៧៩ពេលនោះ ប្រទេសខ្មែរបានជួបប្រទះនូវគ្រោះអាក្រក់,ត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃ នៃពួកជន អ្នកល្មោភអំណាច អ្នកស្រវឹងអំណាច ដ៏មហិមា! មានប៉ុល-ពតជាមេ!និងគូកនខ្លះទៀតបានគ្រប់គ្រងប្រទេស, ឥទ្ធិពលនៃការស្រវឹងអំណាចរបស់ពួកនេះ អស់រយៈពេលត្រឹមតែជាង៣ឆ្នាំប៉ុណ្ណោះបានធ្វើឲ្យជីវិតរបស់ប្រជាពលរដ្ឋស្លូតត្រង់រាប់លាននាក់ស្លាប់បាត់បង់ដោយអយុត្តិធម៌គួរឲ្យអាណោចអធម្មគួរឲ្យសោកស្តាយជាទីបំផុត,ជាមហាសោកនាដកម្មដ៏រន្ធត់តក់ស្លុតយ៉ាងក្រៃលែង!ដែលមិនធ្លាប់មានសោះ ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិនៅលើពិភពលោកយើងនេះ!ការស្រវឹងអំណាចវាមានគ្រោះថ្នាក់ធំធេងយ៉ាងហ្នឹង! ដូច្នេះបានជាព្រះពុទ្ធទ្រង់ទូន្មានថាៈ ជាមនុស្សនៅលើពិភពលោកនេះទាំងមូលកុំផឹកទឹកស្រវឹងនិងកុំស្រវឹងកុំស្រវឹង!។សាធុសប្បុរសទាំងឡាយនិយាយដោយសារុបឡើងវិញ ដើម្បីបញ្ជាប់ថាៈប្រសិនបើមនុស្សទាំងអស់នៅលើពិភពលោកនេះទាំងមូលមានសីល៥នៅក្នុងខ្លួនគ្រប់ៗគ្នា

តាមព្រះពុទ្ធបំណងហើយនោះពិភពលោកនេះទាំងមូលនឹងមានសន្តិភាព”ពិតៗយ៉ាងពិតប្រាកដ!ហើយសេចក្ដីសុខស្ងប់ត្រជាក់ត្រជំសុខក្សេមក្សាន្តសុខសាន្តត្រាណនឹងមានយ៉ាងបរិបូណ៌ឬនឹងហៅថាបានដល់នូវ“ព្រះនិព្វាន”ក្នុងពេលបច្ចុប្បន្ននេះ ក៏សឹងតែថាបាន!។ នេះជារឿងពិត!ជាសច្ចៈធម៌!ពីព្រោះសីល៥វាជារូបមន្តនៃ”សន្តិភាព”ពិតៗយ៉ាងពិតប្រាកដណាស់!។ ការធ្វើអត្ថាធិប្បាយអំពីសិក្ខាបទទាំង ៥ ក្នុងសីល៥ចប់ត្រឹមប៉ុណ្ណេះហោង!ធម៌ស្តីអំពី“សីល”បញ្ចប់ប៉ុណ្ណេះ៕